ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៣

# សេចក្ដីសំរេចលេខ ២៩ សសរ ស្ដីពីការបង្កើត គណៈកម្មការសហប្រតិបត្តិការកម្ពុជា - សិង្ហបុរី

******

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា

- បានឃើញក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា
- បានឃើញសេចក្ដីសំរេចរបស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា លេខ ០៨ សសរ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសំរាប់និតិសម្បទា និង អភិវឌ្ឍន៍
- បានឃើញតម្រូវការចាំបាច់សំរាប់ពង្រីកការងារសហប្រតិបត្តិការ កម្ពុជា សិង្ហបុរី

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការមួយឈ្មោះថា " គណៈកម្មការសហប្រតិបត្តិការកម្ពុជា សិង្ហបុរី " ហៅកាត់ថា " ស.ក.ស ។

**ប្រការ ២ :** សមាសភាពនៃគណៈកម្មការសហប្រតិបត្តិការកម្ពុជា - សិង្ហបុរី មានដូចតទៅ ÷

| | | |
|---|---|---|
| ១ - ឯកឧត្តម ម៉ឹមសុផាណា ទីប្រឹក្សា ឯកឧត្តម ហ៊ុន សែន សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា | | ជាប្រធាន |
| ២ - ឯកឧត្តម ប៉ុក សំអែល | ទីប្រឹក្សាព្រះអង្គស្ដេចក្រុមហ្លួងនរោត្តម រណឫទ្ធិសហប្រធាន រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា | សមាជិក |
| ៣ - លោក អ៊ុត ឈន | ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ចនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤ - លោក សារ៉ាក់ ខាន់ | អ្នកសាយការណ៍នៃគណៈកម្មាធិការជាតិវិនិយោគ | សមាជិក |
| ៥ - លោកស្រី ស៊ិន សិរី | លេខាគណៈកម្មាធិការជាតិសំរាប់និតិសម្បទា និងអភិវឌ្ឍន៍ | សមាជិក |
| ៦ - លោក សេក សេដ្ឋា | តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧ - លោក ជា ប៉េង ឈាង | តំណាងក្រសួងហិរញ្ញវត្ថុ | សមាជិក |
| ៨ - លោក សុខ ចិន្តា | តំណាងក្រសួង ទេសចរណ៍ | សមាជិក |
| ៩ - លោក ឈាង វិបុល | បុគ្គលិកនាយកដ្ឋានផែនការនិងសហប្រតិបត្តិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ ៣ :** គណៈកម្មការសហប្រតិបត្តិការកម្ពុជា - សិង្ហបុរី មានភារកិច្ចដូចតទៅ ÷

- ជំនួយការអោយរដ្ឋាភិបាល និង គណៈកម្មាធិការជាតិសំរាប់និតិសម្បទា និង អភិវឌ្ឍន៍ លើការងារសហប្រតិបត្តិការគ្រប់វិស័យ រវាងកម្ពុជា និង សិង្ហបុរី លើកលែងតែផ្នែកនយោបាយ និងយោធាសន្តិសុខ
- រៀបចំធំរោងសហប្រតិបត្តិការតាមវិស័យនិមួយ ១
- ជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ
- ត្រួតពិនិត្យការអនុវត្តសហប្រតិបត្តិការ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា
- សម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការ កម្ពុជា សិង្ហបុរី
- ធ្វើរបាយការណ៍ជូនរដ្ឋាភិបាល និង គណៈកម្មាធិការជាតិសំរាប់និតិសម្បទា និង អភិវឌ្ឍន៍ តាមកាលកំណត់ ។

ប្រការ ៤ : គណៈកម្មការសហប្រតិបត្តិការកម្ពុជា សិង្ហបុរី មានសិទ្ធិអញ្ជើញឯកឧត្តមអស់លោករដ្ឋមន្ត្រី ឬ តំណាងស្ថាប័ន ដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារ នៃការងារសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដើម្បីចូលរួមបំពេញការងារតាមការជាក់ស្តែង ។

ប្រការ ៥ : សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៦ : គណៈកម្មការសហប្រតិបត្តិការកម្ពុជា សិង្ហបុរី មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ។

ប្រការ ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ និង ឯកឧត្តម អស់លោកដែលមានចែងក្នុងប្រការ២ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * * *